តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

# ការពិពណ៌នាការងារ

| | |
|---|---|
| មុខតំណែង | បុគ្គលិកហាត់ការផ្នែកកម្មវិធី ប្រចាំការិយាល័យខេត្ត ចំនួន០១រូបនៅក្នុងខេត្តនីមួយៗ(ប្រាក់ឧបត្ថម្ភប្រចាំខែ ១៥០ ដុល្លារអាមេរិច) |
| ទីកន្លែងធ្វើការងារ | ខេត្ត បាត់ដំបង សៀមរាប ព្រៃវែង រតនៈគិរី  កំពត និង ធ្វើដំណើរមកកាន់រាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា |
| កម្មវិធី | កម្មវិធីពង្រឹងអភិបាលកិច្ច និងអភិវឌ្ឍសមត្ថភាព |
| រាយការណ៍ជូន | មន្ត្រីសម្របសម្រួលប្រចាំខេត្ត |
| ប្រភេទនៃកិច្ចសន្យា | អ្នកហាត់ការធ្វើការពេញម៉ោង រយៈពេល ៦ខែ (អាចបន្តបាន) |
| ថ្ងៃចាប់ផ្តើម | ខែកក្កដា ២០១៧ |

## ១. ប្រវត្តិសង្ខេប

**អង្គការតម្លាភាពកម្ពុជា** គឺជាតំណាងប្រចាំប្រទេសរបស់អង្គការតម្លាភាពអន្តរជាតិ និងត្រូវបានបង្កើតឡើងជាផ្លូវការកាលពីថ្ងៃទី៥ ខែកក្កដាឆ្នាំ២០១០ ដោយសកម្មជនប្រឆាំងអំពើពុករលួយ និងអ្នកជំនាញដែលបានប្តេជ្ញាចិត្តក្នុងការបង្កើតឲ្យមានតម្លាភាព និងគណនេយ្យភាពនៅកម្ពុជា។ ចាប់តាំងពីកកើតអង្គការតម្លាភាពកម្ពុជាបានក្លាយជាស្ថាប័នដែលឈានមុខគេក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងលើកតម្កើងសុចរិតភាព តម្លាភាព និងគណនេយ្យភាពនៅក្នុងប្រទេស។

ជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រ ពីបច្ចុប្បន្នរហូតដល់ឆ្នាំ ២០២០ របស់អង្គការតម្លាភាពកម្ពុជាបន្ទាប់ពីការផ្តោតលើការលើកកម្ពស់ការយល់ដឹង គឺអង្គការតម្លាភាពកម្ពុជាផ្តោតទៅលើសកម្មភាពជាក់លាក់ផ្នែកតម្រូវការ (អ្នកទទួលសេវា/ប្រជាពលរដ្ឋ) សំដៅចូលរួមធ្វើឲ្យកំណែទម្រង់ផ្នែកផ្គត់ផ្គង់ (អ្នកផ្តល់សេវា)ប្រកបដោយនិរន្តរភាព។ យុទ្ធសាស្ត្រនេះ ផ្តោតសំខាន់លើការផ្តល់អំណាចដល់ប្រជាពលរដ្ឋ ពិសេសយុវជនដែលជាឆ្អឹងខ្នងរបស់ប្រទេសជាតិ ហ៊ានលើកឡើងពីបញ្ហា ក្តីកង្វល់ និងរាយការណ៍ពីអំពើពុករលួយ ដើម្បីចាត់វិធានការរួមគ្នាក្នុងការលើកកំពស់តម្លាភាព សុចរិតភាព អភិបាលកិច្ចល្អ ទំនួលខុសត្រូវសង្គម និងការប្រឆាំងអំពើពុករលួយ។

## ២. គោលដៅរួម

ផ្តល់ការគាំទ្រជាពិសេសផ្នែកកម្មវិធីថ្នាក់ខេត្តរបស់អង្គការតម្លាភាពកម្ពុជាក្នុងការកសាងយុទ្ធសាស្ត្រលើកកម្ពស់សុចរិតភាព តម្លាភាព និងប្រឆាំងអំពើពុករលួយនៅថ្នាក់ក្រោមជាតិ។

## ៣. គោលបំណង

- ផ្តល់ការគាំទ្រដល់មន្ត្រីសម្របសម្រួលថ្នាក់ខេត្ត ក្នុងការទទួលបានលទ្ធផលរំពឹងទុករយៈពេលខ្លី និងរយៈពេលវែងនៅថ្នាក់ក្រោមជាតិ ផ្អែកលើផែនការយុទ្ធសាស្ត្ររបស់អង្គការតម្លាភាពកម្ពុជាដែល

អនុញ្ញាតិដោយគណកម្មការនាយក និងម្ចាស់ជំនួយ

- ជួយដល់មន្ត្រីសម្របសម្រួលថ្នាក់ខេត្តក្នុងការបង្កើតយុទ្ធសាស្ត្រថ្នាក់ខេត្ត/តំបន់ ដោយផ្អែកលើវិធីសាស្ត្រប្រឹក្សាយោបល់ និងការចូលរួមជាមួយនឹងភាគីពាក់ព័ន្ធ និងយុវជន
- ជួយដល់មន្ត្រីសម្របសម្រួលថ្នាក់ខេត្តក្នុងការអនុវត្តន៍សកម្មភាពគម្រោងរបស់អង្គការតម្លាភាពដោយផ្អែកលើយុទ្ធសាស្ត្រអាទិភាពនៅកម្រិតថ្នាក់ខេត្ត ជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗ(អង្គការមិនមែនរដ្ឋាភិបាល រដ្ឋាភិបាល និងអជ្ញាធរមូលដ្ឋាន ក្រុមពលរដ្ឋ/យុវជន និងសហគមន៍នានា)
- ផ្តល់ការគាំទ្រដល់ការបង្កើតការិយាល័យថ្នាក់ខេត្ត និងប្រតិបត្តិការកម្មវិធី និងកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ការិយាល័យថ្នាក់ខេត្ត(ការគ្រប់គ្រងការិយាល័យ និងកិច្ចការហិរញ្ញវត្ថុថ្នាក់ខេត្ត សកម្មភាពក្លឹបយុវជន គំនិតផ្តួចផ្តើមដែលដឹកនាំដោយយុវជន/ពលរដ្ឋ និងការផ្តល់មូលនិធិបន្តដល់ដៃគូក្នុងមូលដ្ឋាន និងសកម្មភាពផ្សេងៗ)

## ៤. ភារៈកិច្ច និងការទទួលខុសត្រូវៈ

### ក. ផ្នែកម្មវិធី

- ក្រោមការណែនាំជាយុទ្ធសាស្ត្ររបស់អ្នកសម្របសម្រួលកម្មវិធី និងក្រោមការគ្រប់គ្រងផ្ទាល់របស់អ្នកសម្របសម្រួលថ្នាក់ខេត្ត ក្នុងការទទួលបានលទ្ធផលរំពឹងទុករយៈពេលខ្លី និរយៈពេលវែងរបស់អង្គការតម្លាភាពកម្ពុជានៅថ្នាក់ក្រោមជាតិ
- ធ្វើការងារយ៉ាងជិតស្និទ្ធជាមួយអ្នកសម្របសម្រួលថ្នាក់ខេត្តដើម្បីបង្កើតការិយាល័យថ្នាក់ខេត្តរបស់អង្គការតម្លាភាពកម្ពុជា និងជួយបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងរួមមាន គណកម្មាការប្រជាពលរដ្ឋ និងក្រុមការងារកម្មវិធី
- ជួយអ្នកសម្របសម្រួលថ្នាក់ខេត្តដើម្បីបង្កើតសកម្មភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពថ្នាក់តំបន់ក្នុងការដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងខេត្ត
- ជួយអ្នកសម្របសម្រួលថ្នាក់ខេត្ត ក្នុងការបង្កើតគណកម្មាការប្រជាពលរដ្ឋ និងក្រុមយុវជនក្នុងសហគមន៍ដែលបានជ្រើសរើស និងបង្កើតរចនាសម្ព័ន្ធការងាររបស់ខ្លួន
- ជួយអ្នកសម្របសម្រួលថ្នាក់ខេត្ត ពិនិត្យការអនុវត្តន៍គម្រោង និងគំនិតផ្តួចផ្តើម/គម្រោងដឹកនាំដោយយុវជន និងធានាប្រសិទ្ធិភាព និងប្រសិទ្ធិផល
- ជួយអ្នកសម្របសម្រួលថ្នាក់ខេត្ត ក្នុងការប្រមូលទិន្នន័យដើម្បីសរសេររបាយការណ៍ ជូនដល់អង្គការតម្លាភាពកម្ពុជាឲ្យបានទៀងទាត់ និងទាន់ពេលវេលា
- ធ្វើការងារយ៉ាងជិតស្និទ្ធជាមួយអ្នកសម្របសម្រួលថ្នាក់ខេត្តដើម្បីពិនិត្យ និងវាយតម្លៃផលប៉ះពាល់/ការផ្លាស់ប្តូរ របស់គម្រោង/គំនិតផ្តួចផ្តើម ជាលទ្ធផលកិច្ចអន្តរាគមន៍របស់អង្គការតម្លាភាពកម្ពុជា និងរាយការណ៍ទៅអង្គការតម្លាភាពកម្ពុជា

### ខ.ផ្នែកប្រតិបត្តិការ

- ជួយមន្ត្រីសម្របសម្រួលថ្នាក់ខេត្ត ជ្រើសរើសបុគ្គលិក អ្នកហាត់ការ និងអ្នកស្ម័គ្រចិត្ត នៅក្នុងខេត្ត

- ជួយអ្នកសម្របសម្រួលថ្នាក់ខេត្តដើម្បីធានាការអនុវត្តន៍គម្រោងក៏ដូចជាការចំណាយផ្សេងៗស្របតាមគោលការណ៍ និងគោលនយោបាយរបស់អង្គការតម្លាភាពកម្ពុជា ក៏ដូចជាម្ចាស់ជំនួយនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល
- រក្សាទុកឯកសារជាអេឡិកត្រូនិក និងឯកសារថតចម្លងអោយបានត្រឹមត្រូវ

### គ.ការទំនាក់ទំនង

- ផ្អែកលើការយល់ព្រមរបស់អង្គការតម្លាភាពកម្ពុជា ធ្វើជាតំណាងរបស់អង្គការតម្លាភាពកម្ពុជា នៅតាមបណ្ដាខេត្តគោលដៅ និងធានាទំនាក់ទំនងជាមួយអ្នកដឹកនាំសហគមន៍ អ្នកពាក់ព័ន្ធ ដៃគូ និងអជ្ញាធរមូលដ្ឋានប្រកបដោយប្រសិទ្ធិភាព
- ធានាទំនាក់ទំនងជាមួយ បុគ្គលិក អ្នកហាត់ការ និងអ្នកស្ម័គ្រចិត្ត ក្រុមប្រជាពលរដ្ឋ និងយុវជនប្រកបដោយប្រសិទ្ធិភាព និងស្អាតស្អំ
- ផ្ដល់របាយការណ៍ និងមតិកែលម្អទៅអ្នកសម្របសម្រួលកម្មវិធី និងមន្ត្រីសម្របសម្រួលថ្នាក់ខេត្តឲ្យទាន់ពេលវេលា
- ត្រូវគោរពតាមគោលនយោបាយទាំងអស់របស់អង្គការតម្លាភាពកម្ពុជា
- ធ្វើការងារផ្សេងៗដែលតម្រូវដោយអ្នកសម្របសម្រួលកម្មវិធី

## ៥. លក្ខណៈសម្បត្តិរបស់បេក្ខជន៖

- កំពុងសិក្សា ឬបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញដែលពាក់ព័ន្ធ
- អតីត ឬបច្ចុប្បន្នជាសមាជិកប្រជាពលរដ្ឋ/ក្រុមយុវជន របស់អង្គការតម្លាភាពកម្ពុជា ដូចជាបុគ្គលិកហាត់ការ អ្នកស្ម័គ្រចិត្ត និងអ្នកដែលបាននិងកំពុងចូលរួមកម្មវិធីភាពជាអ្នកដឹកនាំវ័យក្មេង កម្មវិធីបោះជំរំស្ដីពីការផ្ដល់អំណាចដល់យុវជនដើម្បីតម្លាភាព និងសុចរិតភាព និងគំនិតផ្តួចផ្តើមដឹកនាំដោយយុជន ត្រូវបានលើកទឹកចិត្តជាពិសេស
- ជាប្រជាពលរដ្ឋអចិន្ត្រៃយ៍ និងកំពុងរស់នៅខេត្តគោលដៅនីមួយៗ
- មានបទពិសោធន៍ខ្លះៗក្នុងការអនុវត្តន៍គម្រោងសហគមន៍
- អាចធ្វើការក្រោមសម្ពាធការងារ ការយកចិត្តទុកដាក់ និងប្រឹងប្រែងធ្វើការងារ
- ប្ដេជ្ញាប្រកាន់យកគុណតម្លៃរបស់អង្គការតម្លាភាពកម្ពុជា
- អ្នកអាចនិយាយ និងសរសេរភាសាអង់គ្លេសបានត្រូវបានលើកទឹកចិត្ត